**របាយការណ៍សង្ខេប**

**ស្តីពី**

**វឌ្ឍនភាព និងទិសដៅការងាររបស់ឃុំ ទឹកក្រហម ស្រុកជាំក្សាន្ត**

**ដោយលោក ច័ន សារ៉ុម មេឃុំទឹកក្រហម**

- **អរគុណសន្តិភាព !**
- **អរគុណគោលនយោបាយឈ្នះ ឈ្នះ !**
- **ដឹងគុណ ស្ថាបនិក មគ្គុទ្ទេសក៍ឯក និងប្រតិបត្តិករ នយោបាយឈ្នះ ឈ្នះ ដែលនាំមកនូវសន្តិភាព និងការឯកភាពពេញលេញ !**
- ជាបឋម សូមគោរពឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ជាទីគោរព ដ៏ខ្ពង់ខ្ពស់ !
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ នៃអង្គពិធីទាំងមូលជាទីគោរពស្នេហា !
- ថ្ងៃនេះ ជាថ្ងៃដ៏មហាកិត្តិយសរបស់ខ្ញុំបាទ ដែលឯកឧត្តមប្រធានបានផ្តល់ឱកាសដល់រូបខ្ញុំចូលរួមជាវាគ្មិន នៃសន្និសិទសារព័ត៌មានក្រោមប្រធានបទ “វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅបន្តរបស់រដ្ឋបាលខេត្តព្រះវិហារ ”

ខ្ញុំបាទសូមអនុញ្ញាតិជម្រាបជូននូវរបាយការណ៍វឌ្ឍនភាពសង្ខេបរបស់រដ្ឋបាលឃុំទឹកក្រហម នៃស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម ៖

I- **ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ**

ឃុំទឹកក្រហមជាឃុំមួយ ស្ថិតក្នុងចំណោមឃុំទាំងប្រាំបីនៃស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលមានព្រំប្រទល់ ខាងកើត ជាប់នឹងឃុំមរកត ខាងលិចជាប់នឹងឃុំ ជាំក្សាន្ត ខាងជើងជាប់នឹងប្រទេសថៃ ខាងត្បូងជាប់នឹងឃុំរំដោះស្រែ និងឃុំព្រីងធំ មានផ្ទៃដីសរុបចំនួន ២៥,៦០១ហិកតា ។

រដ្ឋបាលដែនដី បានចែកចេញជា ៧ភូមិ គឺ ភូមិទឹកក្រហម ភូមិចាត់តាំង ភូមិត្រពាំងធំ ភូមិសង្គមថ្មី ភូមិអូរក្សាន្ត ភូមិសែនរុងរឿង១ និងភូមិសែនរុងរឿង៥ ស្ថិតិគ្រួសារនៅក្នុងឃុំ សម្រាប់ឆ្នាំ២០២១ មានចំនួន ១,៩៥០ គ្រួសារ ប្រជាពលរដ្ឋសរុប ៧៧,៦៧នាក់ ក្នុងនោះស្រីចំនួន ៣,៩០៦នាក់។ ក្នុងនោះស្ត្រីជាមេគ្រួសារទូទាំងឃុំ មានចំនួន ៣២២នាក់ ស្មើនឹង១៦ភាគរយ នៃចំនួនប្រជាពលរដ្ឋសរុប។ប្រជាពលរដ្ឋ អាយុ ១៨ឆ្នាំឡើង មានចំនួន ៤,៦០៧នាក់ ស្រី២,៣៣២ នាក់។

ប្រជាពលរដ្ឋមានមុខរបរផ្សេងៗគ្នា ភាគច្រើនមុខរបរ កសិកម្ម ប្រមាណ ៩០% អ្នកចិញ្ចឹមសត្វ និងដំណាំរួមផ្សំ ៤ % ជាមន្ត្រីរាជការមានចំនួន ៦% ។

**II- ផ្នែកសេដ្ឋកិច្ច**

ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចរបស់ឃុំទឹកក្រហម ក្នុងអាណត្តិមុន និងប៉ុន្មានឆ្នាំចុងក្រោយ ក៏ដូចជាបច្ចុប្បន្ននេះ មានហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្នល់ខ្វាត់ខ្វែងគ្រប់ភូមិ ដែលបានប្រែក្លាយពីផ្លូវក្រាលដីស ទៅជាផ្លូវក្រាលក្រួសក្រហម រៀបចំផ្សារសម្រាប់ដោះដូរទំនិញគ្រប់ប្រភេទ ការលើក កម្ពស់សេដ្ឋកិច្ចជូនប្រជាពលរដ្ឋ ដោយក្នុងឃុំយើងមានផ្សារចំនួនមួយ គឺផ្សារអូរជុញ ដែលជាផ្សារទើបនឹងបង្កើតថ្មីក្នុងឆ្នាំ២០១៨ ។

ក្នុងអាណត្តិទី៤ ឃុំទឹកក្រហមបានកសាងផ្លូវដីស និងផ្លូវក្រាលគ្រួសក្រហម សរុបប្រវែង ១០,១៨៧ ម៉ែត្រ លូភ្លោះ ១កន្លែង និងស្ពាន ១កន្លែង និងលូទោលចំនួន ២៥កន្លែង អស់ថវិកាសរុប ៦៧០.៨៥១.៥០០ រៀល បដិភាគចូលរួមពីប្រជាពលរដ្ឋ ចំនួន ៣.៥០០.០០០ រៀល ក្នុងឆ្នាំ២០១៧-២០២១ ។

**III- ផ្នែកសង្គមកិច្ច**

ផ្នែកសង្គមកិច្ច ជាផ្នែកមួយសំខាន់ ដែលលើកយកបញ្ហាសមភាពយេនឌ័រ មកបញ្ជ្រាបចូលគ្រប់សកម្មភាពទាំងអស់ ក្នុងមូលដ្ឋាន ហើយកំពុងបានដោះស្រាយលើគ្រប់វិស័យ ជាពិសេសក្នុងវិស័យសេវាកម្ម កសិកម្ម សុខាភិបាល និងវិស័យអប់រំ ។ ក្រុមប្រឹក្សាឃុំ និងបន្តដោះស្រាយបញ្ហាជាច្រើន នៃការបញ្ជ្រាបយេនឌ័រ នៃគ្រប់ទិដ្ឋភាពទាំងអស់ នៃអភិបាលកិច្ចសង្គម។

បញ្ហាដ៏សំខាន់មួយទៀត គឺត្រូវបង្កើតឲ្យមានតុល្យភាពយេនឌ័រ ដែលប្រកបដោយសមធ៌ម និងមានស្ថិរភាព(រវាងបុរស និងស្ត្រី រវាងក្មេងប្រុស និងក្មេងស្រី)ក្នុងការទទួលបាននូវ សេវាកម្មនានា ការអប់រំ និងសេវាថែទាំសុខភាព ។

ការអប់រំ វាជាតម្រូវការបន្ទាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍន៍ ធនធានមនុស្សនៅក្នុងឃុំ សម្រាប់ការវិនិយោគទៅថ្ងៃអនាគត។ ប៉ុន្តែស្ថានភាពអប់រំនៅក្នុងឃុំមិនទាន់បានល្អប្រសើរនៅឡើយ ដោយសារនៅក្នុងឃុំ ខ្វះសាលាមត្តេយ្យរដ្ឋ មានសាលាបឋមសិក្សារដ្ឋ ចំនួន ៥កន្លែង ស្មើនឹង៣០បន្ទប់ ត្រូវនឹង ៦ថ្នាក់ មានគ្រូបង្រៀនចំនួន ៣៦នាក់ ស្រី២៣នាក់ សិស្សចំនួន ១,០១១នាក់ ស្រី ៥១៨នាក់។

មានអនុវិទ្យាល័យរដ្ឋចំនួន ០១កន្លែង ស្មើនឹង ១២បន្ទប់ មាន ០៣ថ្នាក់ មានសិស្សចំនួន ១១៥នាក់ ស្រី ៥៩នាក់ មានគ្រូបង្រៀនចំនួន ១១នាក់ ស្រី ០៣នាក់។

ដើម្បីអភិវឌ្ឍន៍វិស័យអប់រំនៅក្នុងឃុំ ក្រុមប្រឹក្សាឃុំ បានបង្កើនកិច្ចសហការជាមួយ មេភូមិ នាយកសាលា គ្រូបង្រៀន និងមាតា បិតា អាណាព្យាបាលសិស្ស និងជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ដើម្បីពិគ្រោះរិះរកគ្រប់មធ្យោបាយ ក្នុងការជំរុញឲ្យកុមារទាំងអស់ ទៅរៀនជាប្រចាំឲ្យបានយ៉ាងហោច

ណាស់ចប់កំរិតអនុវិទ្យាល័យ ដោយឃុំលើកគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងត្រៀមបើកវគ្គផ្សព្វផ្សាយដូចខាងក្រោម ៖

- ការផ្សព្វផ្សាយអំពីសុខភាពមាតា និងទារកបានចំនួន២៩វគ្គ ចំណាយអស់ថវិកាមូលនិធិរបស់ឃុំចំនួន ២,៦៦៨,០០០រៀល។
- ការគាំទ្រការធ្វើដំណើរសម្រាប់សំរាលកូននៅមណ្ឌលសុខភាព បានចំនួន ៦១នាក់ ចំណាយថវិកាមូលនិធិឃុំចំនួន ២៤៤,០០០ រៀល។
- ការផ្តល់អាហារូបត្ថម្ភដល់ស្ត្រីក្នុងអំឡុងពេលសំរាលកូននៅមណ្ឌលសុខភាពបានចំនួន ៦៥នាក់ ចំណាយថវិកាចំនួន ២,៦០០,០០០រៀល។
- ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ បានចំនួន ៣២គ្រួសារ ចំណាយថវិកាមូលនិធិឃុំ ចំនួន ១៦,០០០,០០០រៀល។
- ផ្តល់ធុងចម្រោះទឹកស្អាត បានចំនួន ៨៩គ្រួសារ ចំណាយថវិកាចំនួន ៨,៩០០, ០០០រៀល ដែលជាមូលនិធិឃុំ។
- ការប្រជុំរបស់ គ.ក.ន.ក បានចំនួន ៦០លើក ចំណាយថវិកាចំនួន ៤,៨០០,០០០រៀល ដែលជាមូលនិធិឃុំ។
- ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធ និងកិច្ចការពារកុមារ ក្នុងចំណោមកុមារងាយរងគ្រោះបំផុត(ផ្តល់សំលៀកបំពាក់ និងសម្ភារៈសិក្សា) បានចំនួន ១៧១នាក់ ចំណាយថវិកាចំនួន ៦,៨៤០,០០០រៀល ជាមូលនិធិឃុំ ។
- ការអប់រំ និងលុបបំបាត់អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ បានចំនួន ១៨វគ្គ ចំណាយថវិកាចំនួន ៧,២០០,០០០រៀល ជាមូលនិធិឃុំ។
- អប់រំយុវជន យុវនារី អំពីសុខភាពបន្តពូជ និងការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន បានចំនួន ១៨វគ្គ ចំណាយថវិកាចំនួន ៧,២០០,០០០រៀល ដែលជាមូលនិធិឃុំ។
- គាំទ្រការធ្វើដំណើរដល់ជនរងគ្រោះទៅកាន់សេវាសង្គ្រោះ បានចំនួន ១៨នាក់ ចំណាយថវិកាចំនួន ៧២០,០០០រៀល ជាមូលនិធិឃុំ។
- អប់រំ និងលុបបំបាត់អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ បានចំនួន ១៨វគ្គ ចំណាយថវិកាចំនួន១,៦៥៦,០០០រៀល ជាមូលនិធិឃុំ។
- បានផ្សព្វផ្សាយអំពីការទប់ស្កាត់ការឆ្លងជម្ងឺកូវីដ១៩ បានចំនួន ៧២លើក នៅទូទាំងឃុំ។

**យ៉ាងណាមិញក្រៅពីការអនុវត្តមូលនិធិរបស់ឃុំ នៅមានសកម្មភាព**
**របស់មន្ទីរអង្គភាពមួយចំនួន ដែលបានអនុត្តន៍ដូចខាងក្រោម ៖**

- ការអប់រំស្ត្រីឲ្យមកសំរាលកូននៅមណ្ឌលសុខភាព មន្ទីរពេទ្យ បានចំនួន១២លើក អនុវត្តដោយ មន្ទីរសុខភិបាលខេត្ត។
- ផ្សព្វផ្សាយអំពីសុខភាពបន្តពូជ និងព្យាបាលជម្ងឺកាមរោគបានចំនួន ០៨លើក អនុវត្តដោយ មន្ទីរសុខភិបាលខេត្ត។
- ផ្សព្វផ្សាយដល់ស្ត្រីឲ្យមកពិនិត្យផ្ទៃពោះ ៤ដងយ៉ាងតិច បានចំនួន ០៤លើក អនុវត្តដោយ មន្ទីរសុខភិបាលខេត្ត។
- អប់រំស្ត្រី ក្នុងការជំរុញដៃគូរឲ្យពិនិត្យឈាមរកមេរោគអេដស៍ បានចំនួន ០៤លើក អនុវត្តដោយ មន្ទីរសុខភិបាលខេត្ត។
- ផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃការប្រើស្រោមអនាម័យនិងការ ការពារឲ្យបានត្រឹមត្រូវពីជម្ងឺកាមរោគ បានចំនួន ០៤លើក អនុវត្តដោយមន្ទីរសុខភិបាលខេត្ត។
- ចុះដាក់ថ្នាំអាបែតតាមភូមិ បានចំនួន ០១លើក អនុវត្តដោយមន្ទីរសុខភិបាលខេត្ត។

IV- **ផ្នែកធនធានធម្មជាតិ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

- បានចូលរួមវគ្គបណ្តុះបណ្តាល អំពីការបង្ការគ្រោះធម្មជាតិ ចំនួន ០៤វគ្គ
- បានចូលរួមធ្វើអនាម័យជាសាធារណៈ ក្នុងការលើកកម្ពស់បរិស្ថាន ចំនួន ១៨លើក
- បានចូលរួមចែកអំណោយផ្សេងៗ ជាមួយសាខាកាកបាទក្រហមខេត្ត ស្រុកដល់គ្រួសាររងគ្រោះដោយខ្យល់ព្យុះតន្ត្រាក់ និងគ្រួសារក្រីក្រចំនួន ១១លើក ស្មើ ៧២គ្រួសារ។
- បានចូលរួមផ្សព្វផ្សាយ ការធ្វើអនាម័យដល់ប្រជាជនតាមគេហដ្ឋាន ដើម្បីសម្អាតភូមិ ។

V- **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

**១- អំពីរចនាសម្ព័ន្ធក្រុមប្រឹក្សា បុគ្គលិក ការចេញដីកា សេចក្តីសម្រេច និងសេវាសាធារណៈ**

- ក្រុមប្រឹក្សាឃុំ មានចំនួន ៧នាក់ ស្រី ០១នាក់
- មេឃុំ ចំនួន ០១នាក់ (ប្រុស)
- ជំទប់ចំនួន ចំនួន ០២នាក់ ប្រុស០២
- ស្មៀនឃុំ ចំនួន ០១នាក់ (ស្រី)
- មេភូមិ ចំនួន ០៧នាក់ ស្រី ០២នាក់
- អនុភូមិ ចំនួន ០៧នាក់ ស្រី ០១នាក់
- សមាជិកភូមិ ចំនួន ០៧នាក់ ស្រី ០៦នាក់
- ដីកា ដែលបានដាក់ចេញ ចំនួន ១៤ច្បាប់
- សេចក្តីសម្រេច ដែលបានដាក់ចេញ ចំនួន ១៨ច្បាប់
- លិខិតរដ្ឋបាលផ្សេងៗ ដែលបានដាក់ចេញ ចំនួន ១,២៣១ច្បាប់
- លិខិតដែលបានទទួល ចំនួន ១០៩ច្បាប់

- ផ្តល់កាតរីង ដើម្បីបើកប្រាក់ឧបត្ថម្ភដល់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ និងការផ្តល់ប័ណ្ណសមធ៌ម ក្នុងឆ្នាំ២០២១ ដូចខាងក្រោម ៖

១- ផ្តល់កាតរីង ដល់ស្ត្រីមានផ្ទៃពោះចំនួន ៤៣នាក់

២- ផ្តល់កាតរីង ដល់កុមារអាយុក្រោម២ឆ្នាំចំនួន ៤០នាក់

៣- ផ្តល់ប័ណ្ណសមធ៌មតាមការស្នើសុំឆ្នាំ២០២១ ជូនដល់ប្រជាពលរដ្ឋ ចំនួន២០៣នាក់

៤- បានផ្ទៀងផ្ទាត់ប័ណ្ណសមធ៌ម (ប័ណ្ណ២០២០-២០២១) ដើម្បីបើកប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលជូនប្រជាពលរដ្ឋក្នុងអំឡុងពេល កូវីដ ១៩ បានចំនួន ៤៧៧នាក់។

### ២- ការអនុវត្តមុខងារជាផ្លាក់ងារ

#### ក- ការងារអត្រានុកូលដ្ឋាន ឆ្នាំ២០២១

- ចុះសំបុត្រកំណើត បានចំនួន ១២៧នាក់ ស្រី ៧១នាក់
- ចុះសំបុត្របញ្ជាក់កំណើត បានចំនួន ១៧៦នាក់ ស្រី ៧៩នាក់
- ចេញសេចក្តីចម្លងសំបុត្រកំណើតបានចំនួន ៧៩នាក់ ស្រី ៤១នាក់
- ចេញសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតបានចំនួន ១៨នាក់ ស្រី០៩នាក់
- ចុះសំបុត្រអាពាហ៍ពិពាហ៍ បានចំនួន ១២៨គូ
- ចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍បានចំនួន ៤០គូ
- ចុះសំបុត្រមរណភាព បានចំនួន ២០នាក់ ស្រី ០៩នាក់
- ចេញសេចក្តីចម្លងសំបុត្រមរណភាព បានចំនួន ១៧នាក់ ស្រី ៨នាក់

#### ខ- ការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

- ប្រជាពលរដ្ឋបានចុះឈ្មោះថ្មីក្នុងឆ្នាំ២០២១ ចំនួន ១៥៦នាក់ ស្រី ៧៦នាក់
- ប្រជាពលរដ្ឋ ដែលត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ឆ្នាំ២០២១ ចំនួន ៧២នាក់ ស្រី ៤១នាក់។
- ប្រជាពលរដ្ឋសរុប ដែលមានឈ្មោះបោះឆ្នោត(ចាស់ និងថ្មី) មានចំនួន៣,៦៤៥ នាក់ ស្រី ២,០០៧នាក់។

### ៣- កិច្ចសហប្រតិបត្តិការ និងសុខដុមនីយកម្ម ក្នុងសង្គម

- បានធ្វើកិច្ចសហប្រតិបត្តិការ ជាមួយក្រុមប្រឹក្សាឃុំ ក្នុងការផ្តល់សេវាសាធារណៈ ការផ្តល់ផលប្រយោជន៍នានា ពីការអភិវឌ្ឍន៍ និងការផ្តល់កិច្ចគាំពារផ្នែកសង្គម ប្រកបដោយសមធម៌ ដល់គ្រប់ក្រុមប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- បានខិតខំលើកកម្ពស់ការផ្សព្វផ្សាយ និងការអប់រំប្រជាពលរដ្ឋ អំពីផលប្រយោជន៍នៃការរួបរួម និងការរស់នៅប្រកបដោយសុខដុមរមនា ជាមួយគ្នា។

- បានពង្រឹងសុខដុមនីយកម្មជំនឿ និងសាសនាផ្សេងៗគ្នានៅមូលដ្ឋាន ដើម្បីលើកកម្ពស់តំលៃសីលធម៌សង្គម និងគ្រួសារ។
- បានគាំទ្រ និងលើកទឹកចិត្ត ដល់ការបង្កើត និងដំណើរការសហគមន៍នៅមូលដ្ឋាន ព្រមទាំងគាំទ្រដល់សកម្មភាពនានា របស់អង្គការសង្គមស៊ីវិល និងផ្នែកឯកជននានា ដែលប្រតិបត្តិការដើម្បីបំរើការផ្តល់សេវា និងអភិវឌ្ឍនៅក្នុងឃុំ។

**៤- ការងារសន្តិសុខសណ្តាប់ធ្នាប់ និងការដោះស្រាយវិវាទ**

- ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយ ឃុំ បានចំនួន ១៨៦ករណី
- បានចូលរួមវគ្គផ្សព្វផ្សាយ អំពីចលនាប្រឡងប្រណាំងភូមិ ឃុំ មានសុវត្ថិភាព បានចំនួន១៥លើក។
- បានពង្រឹងការអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ
- បានបំផុស និងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមក្នុងចលនាប្រជាការពារដើម្បីរក្សាសន្តិសុខ សុវត្ថិភាព ក្នុងភូមិ ឃុំ។

ដើម្បីឲ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់ក្នុងការបង្ការទប់ស្កាត់ និងលុបបំបាត់ បទល្មើសនានា រដ្ឋបាលសង្កាត់ បានជំរុញអនុវត្តគោនយោបាយភូមិ ឃុំ មានសុវត្ថិភាពអោយសម្រេច បាននូវសំណូមពរទាំង០៩ចំណុច ដូចខាងក្រោម ៖

- គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និង ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្រុមជនទំនើង ក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ បទល្មើសគ្រប់ប្រភេទ។
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាព។
- គ្មានការត្រួតពិនិត្យខុសច្បាប់

កំលាំងប្រជាការពារមាន ៧០នាក់ ស្រី ១១នាក់ ដែលបែងចែកដោយក្រុមប្រឹក្សាឃុំ និងឃាមតាមគោលដៅកំណត់រាងៗខ្លួនតាមភូមិនីមួយៗ បានសហការជាមួយនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ ចុះល្បាតតាមមូលដ្ឋានជារៀងរាល់យប់ ។

VI- **បញ្ហាប្រឈម**

- នៅមានការបំពុលបរិស្ថាន ដោយសារការចោលសំរាមពាសវាលពាសកាល របស់ប្រជាពលរដ្ឋ ព្រោះខ្វះការយល់ដឹងអំពីការធ្វើអនាម័យ និងសេវាកម្មដឹកសំរាមរបស់ក្រុមហ៊ុន មិនទាន់មាន ។
- នៅខ្វះប្រព័ន្ធលូបង្ហូរទឹក
- នៅមាន ការចរាចរណ៍គ្រឿងញៀន ក្នុងមូលដ្ឋាន
- នៅមានគ្រោះថ្នាក់ចរាចរណ៍តិចតួច ដែលបណ្តាលមកពីប្រជាជនយើងខ្លះ មិនទាន់គោរពច្បាប់ចរាចរណ៍មួយរយភាគរយ ជាពិសេសក្រុមយុវជន ។
- ប្រជាពលរដ្ឋមិនសប្បាយចិត្តដោយសារភូមិឃុំ មិនអាចចេញលិខិតបញ្ជាក់ដីជូនគាត់បាន ដើម្បីយកទៅដាក់បញ្ចាំ (ដោយសារដីស្ថិតនៅដែនជម្រក ដែលរាជរដ្ឋាភិបាលមិនទាន់បានកាត់ឆ្វៀលជូន) ។
- ការគ្រប់គ្រងស្ថិតិរបស់ប្រជាពលរដ្ឋមិនទាន់មានភាពងាយស្រួល ពិសេសអត្រានុកូលដ្ឋានមិនទាន់បានចងលក្ខណៈជាប្រព័ន្ធ (ពួកគាត់ច្រើនតែមកបន្លំ កុហកភូមិឃុំ ថាមិនទាន់បានធ្វើ) ។

VII- **ទិសដៅការងារបន្ត**

ទោះបីប្រទេសយើង បានស្ថិតក្នុងដំណាក់កាលប្រយុទ្ធប្រឆាំង និងជម្ងឺកូវីត១៩ ឬការដកប្រព័ន្ធអនុគ្រោះ EBA យ៉ាងណាក្តី ក៏រដ្ឋាភិបាល ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តី ដ៏ឆ្នើមបំផុត របស់កម្ពុជា ក៏នៅតែបន្តវិភាជថវិកាដល់ក្រសួង មន្ទីរ អង្គភាពថ្នាក់ក្រោមជាតិទាំងអស់ ជាពិសេសនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ដើម្បីបន្តការងារបើកផ្តល់ប្រាក់បៀវត្ស ការងារអភិវឌ្ឍន៍នានា ជាធម្មតា។ ជាក់ស្តែង ក្នុងឆ្នាំ២០២២នេះ រដ្ឋបាលឃុំទឹកក្រហម បានទទួលនូវថវិកាវិភាជពីរដ្ឋាភិបាលចំនួន ៦៤៦,២៨៣,៦២០ រៀល ក្នុងនោះថវិកា ២៧៧,៦០០,០០០រៀល សម្រាប់ដំណើរការរដ្ឋបាល និងឧបត្ថម្ភដល់ក្រុមប្រឹក្សាឃុំ និងមន្រ្តីភូមិ ឯថវិកាចំនួន ៣៦៨,៦៨៣,៦២០រៀលទៀត សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន ដែលមានគម្រោង អតិភាពឆ្នាំ២០២២ ដូចខាងក្រោម ៖

- សាងសង់ផ្លូវដីសប្រវែង ៧០០០ម៉ែត្រ ទទឹង ៥,៥០ម៉ែត្រ
- ដាក់លូមូលដោះទឹក៦កន្លែង ប្រវែង ៦ម៉ែត្រ
- ជួសជុលផ្លូវក្រាលគ្រួសក្រហមប្រវែង ៥៥០០ម៉ែត្រ
- ដាក់លូរំដោះទឹកចំនួន ១០កន្លែង

- សាងសង់ស្ពាន១កន្លែង ប្រវែង ១៥ម៉ែត្រ
- សម្រាប់ឆ្នាំបន្តបន្ទាប់ នៅតែបន្តកសាងជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលរួមមានបណ្តាញផ្លូវ ស្ពានគ្រប់ប្រភេទ មានការស្តារឡើងវិញអោយបានឆាប់រហ័ស នូវបណ្តាញផ្លូវលំដែលខូចខាតដោយទឹកជក់ក្នុងឆ្នាំកន្លងមកដើម្បីជានាការធ្វើដំណើរ និងដឹកជញ្ជូនកសិផលរបស់ប្រជាជននៅតាមមូលដ្ឋានទៅកាន់ទីផ្សារ និង កន្លែងដទៃទៀតបានស្រួល និងឆាប់រហ័ស។
- ពង្រឹងការប្រើប្រាស់ផ្លូវ ប្រកបដោយប្រសិទ្ធិភាព ទប់ស្កាត់ការផ្ទុកលើសទំងន់របស់យានយន្តគ្រប់ប្រភេទ លើផ្លូវដែលគ្រប់គ្រងដោយឃុំ។
- ខិតខំបំផុសប្រជាជន សប្បុរសជន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា បន្តចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ និងគ្រប់គ្រងផ្លូវអោយកាន់តែមានលក្ខណៈល្អប្រសើរឡើង ពិសេសកែលំអរជាជំហ៊ានៗ នូវផ្លូវលំពីក្រាលគ្រួសក្រហមទៅជាផ្លូវក្រាលបេតុងអាមេ។
- ជំរុញការចូលរួមពីវិស័យឯកជន ក្នុងការអភិវឌ្ឍន៍ និងថែទាំផ្លូវថ្នល់ព្រមទាំងការផ្តល់សេវាកម្ម ដឹកជញ្ជូននៅក្នុងស្រុក ទីប្រជុំជន និងឃុំ ។
- ជំរុញការផ្សព្វផ្សាយនូវច្បាប់ចរាចរណ៍ផ្លូវគោកឲ្យបានទូលំទូលាយដល់ប្រជាជន អំពីសុវត្ថិភាព នៃការដឹកជញ្ជូន និងពង្រឹងសុវត្ថិភាពចរាចរណ៍។
- ជំរុញការផ្សព្វផ្សាយការធ្វើអនាម័យ ដើម្បីធានាបាននូវសុខមាលភាពល្អ និងបរិស្ថានល្អ ក៏ដូចជាលើកកម្ពស់សោភ័ណ្ឌភាព និងទេសចរណ៍ផងដែរ។
- ធានាឲ្យប្រជាជននៅតាមភូមិនីមួយៗ មានទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ក្នុងជីវភាពប្រចាំថ្ងៃ តាមរយៈការស្តារ ជីកអណ្តូងនិងការដោះស្រាយទឹកតាមមធ្យោបាយផ្សេងៗនៅភូមិដែលខ្វះទឹកប្រើប្រាស់។
- ជំរុញការផ្គត់ផ្គង់ទឹកស្អាត ដែលមានតំលៃសមរម្យ និងប្រើប្រាស់មានអនាម័យ និងផាសុកភាព អោយដល់សហគមន៍មូលដ្ឋាន។
- លើកទឹកចិត្តផ្នែកឯកជន ក្នុងការវិនិយោគលើវិស័យអគ្គីសនី សំដៅជំរុញការផ្គត់ផ្គង់អគ្គីសនី ដែលមានតំលៃសមរម្យ ផ្អែកលើការអភិវឌ្ឍន៍ ប្រភពថាមពល ដែលតភ្ជាប់ពីបណ្តាញជាតិដល់មូលដ្ឋានប្រើប្រាស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី !**

ខាងលើនេះ គឺជារបាយការណ៍សង្ខេប ស្តីពីលទ្ធផល និងសមិទ្ធផលនានា ដែលរដ្ឋបាលឃុំ ទឹកក្រហមសម្រេចបាន ក្រោយប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាឃុំទឹកក្រហម ក្នុងអាណត្តិទី៤នេះ ហើយយើងខ្ញុំទាំងអស់គ្នា ក្នុងនាមតំណាងឲ្យប្រជាពលរដ្ឋមូលដ្ឋាន ក៏ដូចជាការអនុវត្តមុខងារតំណាងរដ្ឋ សូម

ប្តេជ្ញាចិត្តបន្តការផ្តល់សេវាជូនប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរ ឆាប់រហ័ស មានតម្លាភាព និងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខដឹកនាំ និងបន្តការអភិវឌ្ឍន៍មូលដ្ឋានជានិច្ចនិរន្តរ៍។

ជាទីបញ្ចប់ និងក្នុងឱកាសដ៏វិសេសវិសាលនេះ សូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា នៃអង្គពិធីទាំងមូល សូមទទួលបាននូវ ពុទ្ធពរទាំង៤ប្រការ គឺអាយុវណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!